1

# ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

********

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៨២

ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៩

សាលដីកា

លេខ : ១៤២

ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០០១

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០១

ដោយមានសមាសភាពដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ឌិត** | **មុន្ទី** | ជាប្រធាន |
| ២- | លោក | វៀល | មួន | ជាចៅក្រម |
| ៣- | លោក | ស៊ិន | ឌីម | ជាចៅក្រម |
| ៤- | លោក | ជីវ | កេង | ជាចៅក្រម |
| ៥- | លោក | ប្រាក់ | គឹមសាន | ជាចៅក្រម |
| ៦- | លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៧- | លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៨- | លោក | យស់ | សួខឿន | ជាចៅក្រម |
| ៩- | លោក | គង់ | ភិរុណ | ជាចៅក្រម |

ក្រឡាបញ្ជី

លោក ឡេង វុច

តំណាងមហាអយ្យការ

លោក ប៉ែន សាវឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ១៧៣ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ០២ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

- រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ លាន គីវ ភេទស្រី អាយុ ៥៨ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅ ក្រុមទី ៦ ភូមិប្រិយ៍ថ្មី ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប។ ឪពុកឈ្មោះ លាន " ស " ម្តាយឈ្មោះ ញ៉ឹក " ស " ប្តីឈ្មោះ ស្វាង ជុំ ។

- និងចុងបណ្តឹងសាទុក្ខឈ្មោះ ប្រាក់ គឹមថន ភេទប្រុស អាយុ ៥២ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅក្រុមទី៦ ភូមិប្រិយ៍ថ្មី ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប។ ឪពុកឈ្មោះប្រាក់ សួត្រ " ស "

ម្តាយឈ្មោះ នៅ សុំ "ស" ប្រពន្ធឈ្មោះ សម សុទ្ធ ។

មានមេធាវី លោកស្រី ពឹង ធីតា

- អំពីវិវាទ : ប្តឹងសុំសិទ្ធិគ្រប់គ្រងដី

បានឃើញបណ្តឹងសាទុក្ខលេខ ១០៩ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៩ របស់ អ្នកស្រី លាន គីវ ប្តឹងមិនសុខចិត្ត ពីសាលដីការដ្ឋប្បវេណីលេខ ១៧៣ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់ សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ១៨២ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៩-៨-៩៦ របស់ដើមចោទ ប្តឹងសុំសិទ្ធីគ្រប់គ្រងដីមួយប្លង់ ដោយសំអាងហេតុថា : ដីដែលកំពុងមានទំនាស់នេះ ខ្លួនមករស់នៅ និង គ្រប់គ្រង តាំងពីឆ្នាំ ១៩៨២ រហូត មកទល់សព្វថ្ងៃនេះ ថែមទាំងខ្លួនបានធ្វើពាក្យសុំកាន់កាប់ដីរហូត មានទាំងប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើ ប្រាស់ដីធ្លីទៀតផង។ ប៉ុន្តែចុងចម្លើយចេះតែអះអាងថា ដីរបស់គាត់ពីសង្គមចាស់ ហើយទារយកដីពីខ្លួនវិញ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១៤៨ ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ របស់ តុលាការសៀមរាប សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលស្គាល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ $C_{II}$ ០៤៧ ចុះថ្ងៃទី ២៤-១១ ៩៣ មានទំហំ ០០ហិតា ១៤អា ៣៩ សង់ទីអា ដែលមានព្រំប្រទល់ខាងជើងទល់នឹងដីឈ្មោះ អឹម ខន, ខាងត្បូងទល់នឹងផ្លូវជាតិលេខ៦, ខាងកើតទល់នឹង ដីឈ្មោះ លាន គីវ និង ខាងលិចទល់នឹងចូលបារាយណ៍ ជារបស់ឈ្មោះ ប្រាក់ គឹមថន មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣- សំរេចឱ្យឈ្មោះ លាន គីវ សងជំងឺចិត្តចំនួន ៥០០.០០០៛ ឱ្យទៅឈ្មោះ ប្រាក់ គឹមថន សុំ លើសពីនេះលើកចោល ។

៤- សំរេចឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ១.៨០០៛ រង្វាន់ ក្រឡាបញ្ជីកាន់បិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ បូករួម ៧.០០០៛ ប្រាក់នេះបានកាត់ យកពីប្រាក់៧.០០០៛ ដែលដើមចោទបានបង់ទុករួចហើយ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់ឱ្យចុងចម្លើយសង ប្រាក់ ៧.០០០៛ ទៅដើមចោទវិញ និង ឱ្យបង់ពន្ធសមាមាត្រមួយភាគរយ លើតំលៃដី ៣.០០០ដុល្លា បន្ថែម ទៀត ដែលត្រូវដាក់ថវិការដ្ឋ ៨០ភាគរយ និង រង្វាន់ក្រឡាបញ្ជីក្នុងកម្ពុជា ២០ ភាគរយ ពន្ធសមាមាត្រនេះ ត្រូវឱ្យដើមចោទបង់មុនដែរ ទើបបង្គាប់ឱ្យចុងចម្លើយសងទៅដើមចោទវិញ ជាក្រោយ ។

៥- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍ កំណត់ពីខែគិតពី ថ្ងៃនេះតទៅ ។

បានឃើញ បណ្ដឹងឧទ្ធរណ៍ លេខ ២៨ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៦ របស់អ្នកស្រី លាន គីវ ប្ដឹងមិនសុខចិត្ត នឹងសាលក្រមរដ្ឋប្បវេណីលេខ ១៤៨ ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ របស់តុលាការខេត្តសៀមរាប លើគ្រប់ចំណុចវិនិច្ឆ័យទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ២០៧ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៧ របស់ សាលាឧទ្ធរណ៍ សំរេចចំពោះមុខគូក្ដី ដែលមានខ្លឹមសារ នៃ សេចក្ដី សំរេចដូចតទៅ :

១- ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៩-១២-៩៦ របស់ឈ្មោះ លាន គីវ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ អំពីគតិច្បាប់លើកចោលខ្លះ ទុកខ្លះ ។

២- តម្កល់សាលក្រមលេខ ១៤៨ ចុះថ្ងៃទី ០៦-១១-៩៦ របស់តុលាការខេត្តសៀមរាប ទុកជាបានការពេញទាំងមូល តែសំរេចបន្ថែមមួយចំណុចទៀត :

ឱ្យឈ្មោះ ប្រាក់ គឹមថន ចេញសោហ៊ុយសងថ្លៃផលដំណាំឱ្យទៅឈ្មោះ លាន គីវ " ចុងចម្លើយ " ជាប្រាក់មួយលានរៀល " ១.០០០.០០០៛ " ។

៣- សំរេចប្រាក់ប្រដាប់ក្ដី ត្រូវបង់ស្មើគ្នាគឺ ចំនួន ១៣.០០០៛ ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយ គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វឹង ២.៩៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និង អាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។ កាលបើហួសបណ្ដឹងសាទុក្ខបង្គាប់ឱ្យចុងបណ្ដឹងឧទ្ធរណ៍សង ៦.៥០០៛ ទៅដើមបណ្ដឹងឧទ្ធរណ៍វិញ ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី បើផ្លូវប្ដឹងសាទុក្ខរយៈពេលពីរ ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញ បណ្ដឹងសាទុក្ខលេខ១៣៧ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៧ របស់អ្នកស្រី លាន គីវ ប្ដឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ ២០៧ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ លើគ្រប់ចំណុច នៃសេចក្ដីសំរេចទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណី លេខ ២២៥ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ របស់តុលាការកំពូល សំរេចចំពោះមុខគូក្ដី ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :

១- ទទួលបណ្ដឹងសាទុក្ខលេខ ១៣៧ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៧ របស់អ្នកស្រី លាន គីវ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ២០៧ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២១៣ ចុះថ្ងៃទី ២៤-៧-៩៧ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ។

៤- បែងអូសប្រាក់ប្រដាប់ក្ដីចំនួន ១៩.០០០រៀល ដែលអ្នកស្រី លាន គីវ បានបង់រួចហើយគឺ:

- ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល

សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៩.០០០រៀល សរុប ១៩.០០០រៀល ហើយតម្រូវឱ្យលោក ប្រាក់ គីមថន សងប្រាក់ ១៩.០០០រៀល នេះ ទៅអ្នកស្រី លាន គីវ វិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៧។

បានឃើញ ដីកាបញ្ជូន លេខ ១៤ /៩៨ សរណ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ដែលសំរេច បង្វិលសំណុំរឿងលេខ ២១៣ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៧ ទៅសាលាឧទ្ធរណ៍វិញ ដើម្បីចាត់ការតាមច្បាប់ ។

បានឃើញ សាលដីការបៀបលេខ ៣៣ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលសំរេចចាត់របៀប :

១- ចាត់ភ្នាក់ងារភូមិបាលស្រុកពួក ដោយសហការណ៍ជាមួយរដ្ឋអំណាចមូលដ្ឋានចុះវាស់វែង និង គូសផែនទីដីទំនាស់ ចំពោះមុខគូក្តី រវាងឈ្មោះ ប្រាក់ គីមថន និង ឈ្មោះ លាន គីវ ដោយបញ្ជាក់ឱ្យបានច្បាស់ ពីប្រវែងជ្រុង និង ព្រំប្រទល់នីមួយៗ នៃ ដីទំនាស់ តើមានប្រវែងប៉ុន្មាន ទល់នឹងអ្វីខ្លះ រួចជូនលទ្ធផលមកសាលាឧទ្ធរណ៍វិញ ដើម្បីឱ្យសាលាឧទ្ធរណ៍មានមូលដ្ឋានក្នុងការសំរេចសេចក្តី ។

បានឃើញ សាលដីការបៀបលេខ ១៨ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលសំរេចចាត់របៀប :

១- ចាត់បញ្ចូលឈ្មោះ ពេជ ជុន ប្តីឈ្មោះ ស៊ិន កុល ទីលំនៅសព្វថ្ងៃ ភូមិប្រិយ៍ថ្មី ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ជាតតិយជន ក្នុងសំណុំរឿងក្តី រដ្ឋប្បវេណីលេខ ០២ ចុះថ្ងៃទី ១៦-០១-១៩៩៨ របស់សាលាឧទ្ធរណ៍ ។

២- បង្គាប់ឱ្យតតិយជនឈ្មោះ ស៊ិន កុល ជូនសំអាងមកសាលាឧទ្ធរណ៍ ក្នុងរយៈពេល ១៥ថ្ងៃ ចាប់គិតពីថ្ងៃនេះ តទៅ ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ១៧៣ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខឈ្មោះ លាន គីវ , ប្រាក់ គីមថន និង តតិយជនឈ្មោះ ស៊ិន សុកុល ចំពោះមុខមេធាវីឈ្មោះ សុក ហៃ និង ពីង ធីតា ដែលមានខ្លឹមសារ នៃ សេចក្តីសំរេច ដូចតទៅ :

១- ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ ០២ ចុះថ្ងៃទី ១៦-០១-១៩៩៨ របស់សាលាឧទ្ធរណ៍ តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ២២៥ ចុះថ្ងៃទី ២៥-១១-១៩៩៧ របស់តុលាការកំពូល។

២-ក-/ ប្រគល់ដីទំនាស់ទំហំ ABCD ស្ថិតនៅភូមិប្រិយ៍ថ្មី ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប តាមប្លង់បង្ហាញទីតាំងដីទំនាស់ ចុះថ្ងៃទី ១១-១២-១៩៩៨ ទៅឱ្យឈ្មោះ ប្រាក់ គីមថន កាន់កាប់ និង គ្រប់គ្រងជាកម្មសិទ្ធិនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

ខ-/ ប្រគល់ដីទំនាស់ទំហំ ADEFG ស្ថិតនៅភូមិប្រិយ៍ថ្មី ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប តាមប្លង់បង្ហាញទីតាំងដីទំនាស់ចុះថ្ងៃទី ១១-១២-១៩៩៨ ទៅឱ្យឈ្មោះ ប្រាក់ គីមថន កាន់កាប់ និង គ្រប់

ត្រង់ជាកម្មសិទ្ធិនៅពេល ដែលសាលដីកានេះ ចូលជាស្ថាពរ ។

គ-/ អនុញ្ញាតឱ្យឈ្មោះលាន គីវ លេះដំណាំស្វាយ និងដូងចាស់ នៅលើដីទំនាស់ទំហំ ADEFG រហូតដល់ដើមឈើនេះ ចាស់ងាប់ ។

៣- បង្គាប់ឱ្យឈ្មោះ លាន គីវ បង់ពន្ធសមាមាត្រ ១% លើតម្លៃដីដែលបានសំរេចក្នុងចំណុចទី ២ " ក " និង " ខ " នៃ សាលដីកានេះ ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខឈ្មោះ លាន គីវ , ប្រាក់-គឹមថន និង តតីយជនឈ្មោះ ស៊ិន សុកុល ចំពោះមុខមេធាវីឈ្មោះ សុក ហៃ និង ពឹង ធីតា ។

- បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ១០៩ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៩ របស់អ្នកស្រី លាន គីវ ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ១៧៣ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ លើត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ០៧-១២-១៩៩៩ របស់អ្នកស្រី លាន គីវ

បានឃើញ សារណាតប ចុះថ្ងៃទី ២១-៦-២000 របស់ លោក ប្រាក់ គឹមថន

បានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា :

- បណ្តឹងសាទុក្ខរបស់ ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា។

- សាលដីការដ្ឋប្បវេណីលេខ ១៧៣ ចុះថ្ងៃទី ០៦-៤-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី លាន គីវ ឆ្លើយថា : ឈ្មោះ ម៉ៅ ឡាត់ បានប្រគល់ដីមកឱ្យខ្លួនវិញ ហើយក៏ចេញទៅទិញផ្ទះរបស់យាយម៉ាប់ តែក្រោយមកឈ្មោះ ប្រាក់ គឹមថន បានទៅទិញផ្ទះរបស់យាយម៉ាប់ទៀត រួចទើបលួចធ្វើប័ណ្ណកម្មសិទ្ធិរំលោភលើដីរបស់ឈ្មោះ ពេជ្រ ផុន ដែលគេសុំខ្លួនស្នាក់នៅ ពេជ្រ ផុន បានបញ្ជាក់ប្រាប់ ប្រាក់ គឹមថន ថា ជាដីរបស់ខ្លួនទេ ។

ខ្លួនប្តឹងទាមទារដីនេះ ទៅតាមច្បាប់កំណត់ឱ្យ ។

បានស្តាប់ចម្លើយរបស់លោក ប្រាក់ គឹមថន ឆ្លើយថា : ការធ្វើប័ណ្ណកម្មសិទ្ធិនេះ ខ្លួនបានដាក់ពាក្យនៅឆ្នាំ៨៩ ដល់ទៅឆ្នាំ ៩៣ ទើបចេញប័ណ្ណកម្មសិទ្ធិនេះ ឱ្យដោយប្លង់នេះ មានទំហំដី ១៤៦០ម២ រួមទាំងដីរបស់ ពេជ្រ ផុន ផង ហើយគាត់ក៏បានយល់ព្រមឱ្យខ្លួនធ្វើដែរ ដោយមានសាក្សីឈ្មោះ អ៊ឹម ឧន , សុខ ទៀង និង កែ ឈាន បញ្ជាក់ថា ខ្លួនបានធ្វើប័ណ្ណកម្មសិទ្ធិស្របតាមច្បាប់ពេល ពេជ្រ ផុន បានប្រគល់ដីឱ្យខ្លួន គឺ គ្មានការដោះដូរអ្វីទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី លោក តង់ សុភ័ក្ត្រ បញ្ជាក់ថា :

ខ្ញុំបាទសូមនិយាយដំណើរហេតុបន្តិច ដីលំនៅដ្ឋាន និង ដីស្រែ ដែលមានទំហំប្រមាណ ៦.០០០ម² ស្ថិតនៅភូមិប្រិយ៍ថ្មី ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ត្រូវបានអ្នកស្រី លាន គីវ ចូលមករស់នៅគ្រប់គ្រងកាន់កាប់ ចាប់តាំងពីឆ្នាំ ៧៩ រហូតមកទល់បច្ចុប្បន្ន ។ ក្នុងការរស់នៅនេះ កូនក្តីខ្ញុំបាទបានប្រើប្រាស់ចាក់ចែង លើដីនេះ ដូចជា ធ្វើស្រែ ដាំដំណាំ និង ប្រមូលផលជារៀងរាល់ឆ្នាំ ។

សូមឯកឧត្តមមេត្តា ពិនិត្យលើឯកសារលេខ : ១៥ ដល់ឆ្នាំ ១៩៨៩ ឈ្មោះ ជ័យ យ៉េន និង ម៉ៅ ឡាត បានប្រគល់ដីឱ្យអ្នកស្រី លាន គីវ វិញ តែឈ្មោះ ប្រាក់ គឹមថន បានឈ្លាតឱកាសធ្វើប័ណ្ណកម្មសិទ្ធិលើដីដែលឈ្មោះ ទាំងពីរនេះ ប្រគល់ឱ្យអ្នកស្រី លាន គីវ វិញ ដោយមានឯកសារបញ្ជាក់លេខ : ៣២, ៣៣, ៣៤, និង ៤០ ។

ពេលធ្វើប័ណ្ណនេះ គឺមានការចុះវាស់វែង និង ចុះអង្កេតបានច្បាស់លាស់ណាស់ នៅក្នុងកំណត់ហេតុអង្កេតនោះ គឺសុទ្ធតែត្រូវបានទទួលស្គាល់ពីរដ្ឋអំណាចទាំងអស់ ។

បើពិនិត្យ និង ប្រៀបធៀបទៅលើការបញ្ជាក់អំពីព្រំប្រទល់លើប័ណ្ណរបស់ ប្រាក់ គឹមថន វិញ គឺមានលក្ខណៈផ្ទុយគ្នាស្រឡះ នៅក្នុងពាក្យសុំកាន់កាប់របស់ប្រាក់ គឹមថន បានបញ្ជាក់ថា ខាងកើតទល់ និង ភូមិសណ្ឋាន់ ឯកំណត់ហេតុវាស់វែងបានបញ្ជាក់ថា ខាងកើតទល់និង លាន គីវ ទៅវិញ ដូច្នេះការសំរេចចេញប័ណ្ណកម្មសិទ្ធិឱ្យ ប្រាក់ គឹមថន គឺ ផ្ទុយពីគោលការណ៍ច្បាប់ទាំងស្រុង ។

កំណត់ហេតុអង្កេត ចុះថ្ងៃទី ២៦-០៩-១៩៩៣ ដែលបង្ហាញជូនតុលាការនេះ គឺ ជាកំណត់ហេតុតែបន្ទំសុទ្ធសាធ ករណីនេះបានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់អ្នកស្រី លាន គីវ យ៉ាងខ្លាំង ហើយក៏រំលោភទៅនឹងមាត្រា ៦១, ៦២ និង ៧៤ នៃច្បាប់ភូមិបាល ។

**<u>សំណូមពរ</u> :**

- សូមមេត្តាបដិសេធសាលដីការបស់សាលាឧទ្ធរណ៍
- សូមសំរេចជាថ្មីតាមសាលដីកា ដែលមានគតិយុត្តិធម៌បំផុត ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី លោកស្រី ពីង ធីតា បញ្ជាក់ថា :

ដីដែលមានទំនាស់សព្វថ្ងៃ គឺមានទំហំ១៤៦០ម² តាំងពីឆ្នាំ៧៩ រហូតដល់បច្ចុប្បន្ន កូនក្តីរបស់នាងខ្ញុំ បានដាក់ពាក្យសុំសិទ្ធិកាន់កាប់ ដែលមានប័ណ្ណលេខ : $C_{II}$ ០៤៧ ចុះថ្ងៃទី ២៣-១១-៩៣ ដែលមានការចុះវាស់វែងត្រឹមត្រូវតាមច្បាប់ ដូច្នេះ សូមឯកឧត្តម មេត្តាពិនិត្យ ចំពោះពាក្យមេធាវី ដែលបានលើកឡើងមុននេះ ។

ទំហំដីរបស់គាត់នៅក្នុងប័ណ្ណមាន តែ២.០០០ម² ដូចពាក្យមេធាវីរបស់ លាន គីវ ថា មានទំហំ ៦.០០០ម² ចុះហេតុអ្វី នៅក្នុងប័ណ្ណមានតែ ២.០០០ម² វិញ សូមឯកឧត្តមពិចារណា ។

ស៊ិន កុល បានបញ្ជាក់យ៉ាងច្បាស់ថា ដីនេះ ជារបស់ឈ្មោះ ប្រាក់ គឹមថន ហើយឪពុករបស់ខ្លួនសុំ ប្រាក់ គឹមថន សង់ផ្ទះស្នាក់នៅបណ្តោះអាសន្នលើដីនោះ ហើយសព្វថ្ងៃ គេបានរុះផ្ទះរបស់គេចេញ

ពីដីរបស់ ប្រាក់ គឹមថន ហើយ បន្ទាប់ពីសាលាឧទ្ធរណ៍សំរេចហើយ ដូច្នេះសល់ដីគឺជា ដីរបស់កូនក្តីខ្ញុំទេ ។ ដីទំាងបី ប្លង់នេះ សុទ្ធតែមានប័ណ្ណទំាងអស់ ហើយមានការបំភ្លឺពីស្នងការខេត្ត ទំាងនេះហើយ ដែលបញ្ជាក់ថា លោក ប្រាក់ គឹមថន បានធ្វើឡើងត្រឹមត្រូវតាមច្បាប់ មិនបានរំលោភទៅលើដីរបស់អ្នកស្រី លាន គីវ ឡើយ ដែលស្របតាមមាត្រា ១ និង ៧៤ នៃច្បាប់ភូមិបាល គឺមានលក្ខណៈគ្រប់គ្រាប់ក្នុងការកាន់កាប់ជាកម្មសិទ្ធិហើយ ។

**សំណូមពរ :**

សូមឯកឧត្តម មេត្តាផ្តល់ដីឱ្យកូនក្តីរបស់នាងខ្ញុំតាមប័ណ្ណកម្មសិទ្ធិស្របច្បាប់ និង សូមតម្កល់សាលដីកាលេខ : ១៨៣ ចុះថ្ងៃទី ០៦-៤-៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការទំាមូល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូក្តី និង សេចក្តីសន្និដ្ឋាន របស់មេធាវីនៃ គូភាគី .
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

# តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខ លើកទី២ លេខ ១០៩ ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ១៩៩៩ របស់អ្នកស្រី លាន គីវ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើកឡើងរឿងនេះ មកជំនុំជំរះដល់អង្គសេចក្តី បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២២៦ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សំរេចប្រគល់ដីទំនាស់ទំហំ ADEFG ស្ថិតនៅភូមិប្រិយ៍ថ្មី ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប តាមប្លង់បង្ហាញទីតាំងដីទំនាស់ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ១៩៩៨ ឱ្យឈ្មោះប្រាក់ គឹមថន កាន់កាប់និងគ្រប់គ្រងជាកម្មសិទ្ធិនោះ ជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា ការសំរេចនេះ បំពានទៅលើដី ដែលកាន់កាប់ និង រស់នៅរបស់អ្នកដទៃ ។

- យល់ឃើញថា ដើមឡើយ ដីទំនាស់ត្រូវបានរស់នៅ និងកាន់កាប់ ដោយលោក ម៉ៅ ឡាក់ និង ជ័យ យ៉េន ហើយនៅឆ្នាំ ១៩៨៩ ឈ្មោះ ទំាងពីរខាងលើ បានប្រគល់ដីនេះ ឱ្យម្ចាស់ដើមវិញ គឺអ្នកស្រី លាន គីវ ដូច្នេះអ្នកស្រី លាន គីវ ដែលធ្លាប់បានអាស្រ័យផលលើដំណាំចាស់ផងនោះ មានសិទ្ធិលើដីផ្នែកនេះ តាមច្បាប់ ។

- យល់ឃើញថា ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ $C_{II}$ ០៤៧ ចុះថ្ងៃទី ២៤-

១១-៩៣ របស់លោក ប្រាក់ គឹមថន ធ្វើឡើងបំពានទៅលើដីរបស់អ្នកស្រី លាន គីវ ហើយកំណត់ហេតុអង្កេត ក៏ពុំមានស្នាមមេដៃសាក្សី, អ្នកជាប់ព្រំប្រទល់ និង ចុះហត្ថលេខារដ្ឋអំណាច ភូមិឃុំទេ ។ ដូច្នេះគប្បីតុលាការសំរេចទុកជាមោឃៈ ។

- យល់ឃើញថា ឈ្មោះ ប្រាក់ គឹមថន មានសិទ្ធិពេញទី តែលើដីទំហំផ្នែក ABCD ដែលខ្លួនកំពុងរស់នៅ និង កាន់កាប់ប៉ុណ្ណោះ គឺពុំមានសិទ្ធិកាន់កាប់ដីទំហំផ្នែក ADEFG ដែលខ្លួនពុំដែលបានថែរក្សាកាន់កាប់នោះទេ ។

- យល់ឃើញថា ឈ្មោះ ពេជ្រ ផុន និង ប្រពន្ធឈ្មោះ ស៊ិន សុកុល បានទទួលស្គាល់ថាខ្លួនបានសុំដី របស់ចុងចម្លើយស្នាក់នៅក្នុងឆ្នាំ ១៩៨៧ មែន ហើយប័ណ្ណកម្មសិទ្ធិរបស់ឈ្មោះ ប្រាក់ គឹមថនពិតជាធ្វើរំលងផ្ទះខ្លួនប្រាកដមែន ចម្លើយនេះអាចយកជាការបាន ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៧៣ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខចុងចម្លើយ

១- ទទួលបណ្តឹងសាទុក្ខលេខ ១០៩ ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ១៩៩៩ របស់អ្នកស្រី លាន គីវ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ខ្លះ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១៧៣ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុច ២ - ខ, គ និង ចំណុចទី ៣, ចំណុចទី ២ ( ក ) តម្កល់ទុកនៅដដែល ។

៣- ប្រគល់ដីទំនាស់ទំហំADEFG ស្ថិតនៅភូមិប្រិយ៍ថ្មី ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប តាមប្លង់បង្ហាញទីតាំងដីទំនាស់ ចុះថ្ងៃទី ១១-១២-១៩៩៨ ឱ្យអ្នកស្រី លាន គីវ កាន់កាប់ និង គ្រប់គ្រងអាស្រ័យផលតទៅ ។

៤- ទុកជាមោឃៈ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ $C_{II}$ ០៤៧ ចុះថ្ងៃទី ២៤-១១-៩៣ ចោលជាអសារបង់ ហើយសាមីខ្លួនត្រូវសុំប័ណ្ណសំគាល់សិទ្ធិថ្មី តាមទំហំដីដែលតុលាការសំរេចប្រគល់ឱ្យ ។

៥- រំលងអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលអ្នកស្រី លាន គីវ បានបង់រួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតម្រូវឱ្យឈ្មោះ ប្រាក់ គឹមថន សងប្រាក់ ១៩.០០០រៀល នេះ ឱ្យអ្នកស្រី លាន គីវ វិញ ។

បង្គាប់ឱ្យ ឈ្មោះ ប្រាក់ គីមថន បង់ពន្ធសមាមាត្រមួយភាគរយ លើតម្លៃដីជាក់ស្តែង ដែលបានសំរេចប្រគល់ឱ្យអ្នកស្រី លាន គីវ និង សំរេចឱ្យអ្នកស្រី លាន គីវ បង់ពន្ធសមាមាត្រ ១% លើចំណែកដីដែលត្រូវបានទៅលោក ប្រាក់ គីមថន ។

៦- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០០១ ។